Sourn Serey Ratha

ថ្ងៃទី ១២ ឧសភា ២០១៦,

សេដ្ឋកិច្ចរបស់ប្រទេសខ្មែរ ក្រោមការដឹកនាំរបស់លោក ហ៊ុន សែន គឺជា «សេដ្ឋកិច្ចអំណាចសេរី» មិនមែនជា «សេដ្ឋកិច្ចទីផ្សារសេរី» ទេ ! ។

សេដ្ឋកិច្ចអំណាចសេរី គឺគេយកអំណាច បក្ខពួកគ្រួសារ ជាធំ មិនមែនយកច្បាប់ជាធំទេ ។ អ្នកណាមានអំណាច គឺធ្វើអ្វីក៏បានតាមអំពើរដោយសេរី គ្មានខ្លាចញញើតច្បាប់ឡើយ ។ ទោះជាចង់ជីកគាស់កាយ រំលើងភ្នំ បូមដីចាក់លុបបឹង និងចុះកិច្ចសន្យាលក់អស់ខ្ទេចអស់ខ្ទី ក៏មិនមានទោសដែរ ។ ក្រៅពីប្រើអំណាចមកត្រួតបញ្ជាពីលើច្បាប់ នៅមានប្រើឥទ្ធិពលគ្រួសារមកត្រួត កាន់កាប់ក្រសួង មន្ទី និងស្ថាប័នរដ្ឋតាមអំពើចិត្ត ។ ដីធ្លីស្រុកខ្មែរ ជាង ៩០% ជាកម្មសិទ្ធិផ្តាច់មុខរបស់ក្រុមមនុស្សប្រហែល ១០០០ គ្រួសារប៉ុណ្ណោះ ហើយបុរី វីឡា ផ្សារ ផ្ទះល្វែង ដែលសាងសង់ ៩០% គឺជាកម្មសិទ្ធិរបស់ក្រុមគ្រួសាររបស់ពួកមន្ត្រីពុករលួយដែលមានអំណាច និងពួកឈ្មួញទុច្ចរឹតដដែលៗ ដែលក្រុមដង្កូវសង្គមប៉ុណ្ណោះ ។

សេដ្ឋកិច្ចអំណាចសេរី មើលទៅល្អភ្នែក គឺបានត្រឹមតែល្អមើលប៉ុណ្ណោះ តែមិនអាចជួយឃឹតយោងជីវភាពរបស់ពលរដ្ឋខ្មែរឲ្យរីកចម្រលនបានទេ ។ ពលរដ្ឋខ្មែរ អ្នកធ្វើស្រែចម្ការ ប្រមូលផលមក គ្មានទីផ្សាសម្រាប់លក់ ធ្វើស្រែ ធ្វូលចម្ការយូរៗទៅ លក់ដីស្រែ ដីចម្ការយកទៅសងបំណុលធានាគាមិនរួចខ្លួន ។ ចំណែកធានាគា និងគ្រឹះស្ថានហិរញ្ញវត្ថុ ព្រមទាំងអង្គការឥណ្ឌទានមួយចំនួន ដើរតួរនាទីជាចោរចាប់ជំរឹតស្របច្បាប់ដោយសេរី ។ គឺជំរឹតសេរី យកផ្ទះសំបែង ដីធ្លី ស្រែចម្ការ របស់ពលរដ្ឋខ្មែរ ដោយគ្មានច្បាប់ការពារការក្ស័យធន់ ។

នេះជាសេដ្ឋកិច្ចអំណាចសេរី នៅក្នុងប្រទេសខ្មែរ ដែលគេធ្វើដើម្បីដេញអ្នកក្រឲ្យរត់ចោលស្រុក ឲ្យចំណាកស្រុក និងឲ្យស្លាប់ ដើម្បីលុបបំបាត់អ្នកក្រ ! ៕